# ប្រមូលវប្បធម៌ខ្មែរ

## (ដកស្រង់ពីវចនានុក្រមខ្មែររបស់សម្តេចជួន-ណាត
## និង វចនានុក្រមខ្មែរ-អង់គ្លេស)

### កក់

(ឈ្មោះស្មៅទឹកមួយពួកសម្រាប់ប្រើជារបរធ្វើកន្ទេល)

កក់ មានច្រើនប្រភេទ : (ទំ.១)

- កក់ មូល
- កក់ ជ្រុង
- កក់ ចែងម៉ែង

### កង្កែប

(ឈ្មោះសត្វទឹកមួយប្រភេទមានជើងបួនចេះហែលទឹក មុជទឹក លោតលើគោកក៏បាន ច្រើននៅអាស្រ័យនឹងទីក្បែរមាត់ទឹក ឬនឹងរន្ធដីក៏នៅបាន)

កង្កែប មាន៣ប្រភេទ : (ទំ.៤)

- កង្កែប កូប (មានរូបធំយំឮសូរកូបៗ)
- កង្កែប ប្រុយ (មានតូចដងខ្លួនវែង ជើងវែងៗ អ្នកខ្លះហៅ កូនស្ទើន)
- កង្កែប អាចម៍គោ (មានប៉ុនគ្នានឹងកង្កែបប្រុយ ប៉ុន្តែដងខ្លួនខ្លី ជើងក៏ខ្លីដែរ សម្បុរស្ទើរលឿងនៅតែក្នុងកំពាយអាចម៍គោលើគោក)

### កណ្តុរ

(សត្វចតុប្បាទតូចមួយប្រភេទក្នុងពួកសត្វមានដោះ ជាសត្វឱ្យទុក្ខដល់មនុស្សដោយហេតុបំផ្លាញមានកាត់សំពត់អាវជាដើម)

កណ្តុរ មានច្រើនប្រភេទ : (ទំ.១២)

- កណ្តុរ ល្មែះ
- កណ្តុរ ប្រែង
- កណ្តុរ បង្កង់
- កណ្តុរ ស្រែ

### កន្ទេល

(កម្រាលត្បាញដោយបន្ទោះផ្សេងៗ)

កន្ទេល មានច្រើនប្រភេទ : (ទំ.១៨)

- កន្ទេល ក្រហម
- កន្ទេល ចចូត
- កន្ទេល រំចេក

- កន្ទេល រុន
- កន្ទេល ផ្តៅ
- កន្ទេល ផែង

**កន្ទួត**

(ឈ្មោះឈើមានផ្លែមានរសជូរប្រើបរិភោគបាន)

កន្ទួត មាន២ប្រភេទ : (ទំ.១៨)

- កន្ទួត ស្រុក
- កន្ទួត ព្រៃ

**ក្រុក**

(ឈ្មោះសត្វបក្សីមួយពួកចាប់ត្រីរស់ជាអាហារ)

កុក មានច្រើនប្រភេទ : (ទំ.៤០)

- កុក គ្រោង
- កុក ក្រក
- កុក សាប់
- កុក ស

**កែស**

(ឈ្មោះត្រីរំអិលមួយប្រភេទសណ្ឋានដូចត្រីក្លាំងហាយ)

ត្រីកែស មាន៣ប្រភេទ : (ទំ.៥០)

- កែស ធម្មតា (រូបតូចល្មម)
- កែស ជម្រៅ (ធំជាងបន្តិច)
- កែស ប្រាក់ (ធំជាងនោះទៅទៀត)

**កំពឹងពួយ** (ស្មៅវារ ដុះអណ្តែតលើទឹក ឬដុះនៅលើដីសើម មានឫសចេញពីថ្នាំង មានស្លាប់ពណ៌ស ឱបទង ផ្កាតូច ស ឬក្រហម ប្រើជាអន្លក់)

កំពឹងពួយ មាន២ប្រភេទ : (ទំ.៦០)

- កំពឹងពួយ ឈើ
- កំពឹងពួយ អំបោះ

**កាំបិត** (ប្រដាប់ធ្វើដោយដែកមានមុខម្ខាង មានដងម្ខាង តូចក៏មាន ធំក៏មាន សណ្ឋានផ្សេងៗសម្រាប់ប្រើកាប់,កាត់,បិត,ចិត,អារ,ពន្លះជាដើម)

កាំបិត មានច្រើនប្រភេទ : (ទំ.៦៣)

- កាំបិត ចែត
- កាំបិត ព្រា
- កាំបិត បន្ទោះ
- កាំបិត ស្លា
- កាំបិត ប៉ុងតោ
- កាំបិត កោរ
- កាំបិត បត់
- កាំបិត ស្នៀត

**ក្តាម** (ឈ្មោះសត្វមានស្នូក ជើង១០ ភ្នែកលៀន)

ក្តាម មានច្រើនយ៉ាង : (ទំ.៦៥)

- ក្តាម គ្រោង
- ក្តាម ស្រែង
- ក្តាម សេះ

- ក្តាម ស្រែ

**ក្របី** (ឈ្មោះសត្វពាហនៈចតុប្បាទ ស្នែងវែងវៀវស្រួច មានរង្វង់កោង ជាពាហនៈសម្រាប់ទឹមដូចគោដែរ)

ក្របី មាន២យ៉ាង : (ទំ.៧៤)

- ក្របី ខ្មៅ (សម្បុរខ្មៅ)
- ក្របី ឈ្មៀច (សម្បុរ ស បុរាណហៅ ក្របី)

**ក្រឹម** (ឈ្មោះត្រីមួយពួកតូចៗ)

ត្រីក្រឹម មាន៣យ៉ាង : (ទំ.៨៦)

- ត្រីក្រឹម មាស (សម្រាប់ផល់)
- ត្រីក្រឹម ទន្សាយ (មិនចេះផល់ទេ)
- ត្រីក្រឹម ក្តារ (មិនចេះផល់ទេ)

**ក្រូច**

(ឈ្មោះឈើមួយពួកមានផ្លែប្រកបដោយក្លែប, កំពឹសមានរសជូរឬផ្អែម សម្រាប់ប្រើជាអាហារ ឬជាប្រយោជន៍ក្នុងគ្រឿងញាំភ្លាជាដើម)

ក្រូច មានច្រើនយ៉ាង : (ទំ.៨៧)

- ក្រូច ថ្លុង
- ក្រូច សើច
- ក្រូច ឆ្មារ
- ក្រូច ចងសក់
- ក្រូច ឃ្វិច
- ក្រូច ពោធិសាត់
- ក្រូច ញាំ
- ក្រូច បាត់ដំបង
- ក្រូច ព្រៃ
- ក្រូច ភ្លា
- ក្រូច សំរែ
- ក្រូច សំសា
- ក្រូច ទេពារស
- ក្រូច ចិន

**ខ្នុរ** (ឈ្មោះឈើដំណាំមួយប្រភេទ មានផ្លែជាអាហារ ខ្លឹមប្រើស្ងោរ យកទឹកជ្រលក់សំពត់ចីវរអ្នកបួស ក្នុងព្រះពុទ្ធសាសនា)

ខ្នុរ មានច្រើនយ៉ាង : (ទំ.១១០,ទំ.១៥៣៨,ទំ.១៧១៦)

- ខ្នុរ ណាំងរមៀត
- ខ្នុរ ណាំងល្មុត
- ខ្នុរ ណាំងស្បែក
- ខ្នុរ បាយស្រោ
- ខ្នុរ អាចម៍ដី
- ខ្នុរ មូលដី ឬ ខ្នុរ ម្រេច
- ខ្នុរ ព្រៃ
- ខ្នុរ សម្ល

**ខ្យង** (ឈ្មោះសត្វសន្តានខឹងសំង្ខ សំបកសន្តានខ្ចៅ តែរូបធំជាងខ្ចៅ)

ខ្យង មានច្រើនយ៉ាង : (ទំ.១១៣)

- ខ្យង គូទស្រួច
- ខ្យង គូទទាល

- ខ្យង អាចម៍ដី
- ខ្យង ហៀន
- ខ្យង រុន
- ខ្យង ភ្នែកប្រើស
- ខ្យង ថ្កក់
- ខ្យង ត្រី
- ខ្យង ត្នោត
- ខ្យង ក្បុង
- ខ្យង ខ្មៅ

**ខ្លា** (ឈ្មោះសត្វចតុប្បាទសាហាវ រូបរាងដូចឆ្មាតែធំជាង តែង នៅក្នុងព្រៃ បរិភោគសាច់)

ខ្លា មានច្រើនប្រភេទ : (ទំ.១១៩)

- ខ្លា ឃ្មុំ
- ខ្លា ដំបង
- ខ្លា រខិន ឬ ខ្លា តាខិន
- ខ្លា ត្រី
- ខ្លា ធំ

**ខ្វិត** (ឈ្មោះឈើមានផ្លែបរិភោគបាន សន្តាននឹងក្រសាំង)

ខ្វិត មាន២ប្រភេទ : (ទំ.១១៧)

- ខ្វិត ធំ (ផ្លែធំ)
- ខ្វិត តូច ឬ ខ្វិត ធម្មតា (ផ្លែតូច)

**ខ្ទីង** (ឈ្មោះសត្វព្រៃចតុប្បាទ រូបសណ្ឋានដូចក្របី)

ខ្ទីង មានច្រើនប្រភេទ :

- ខ្ទីង ក្របី
- ខ្ទីង ជំរ
- ខ្ទីង ពស់
- ខ្ទីង ស្លឹក

**ខ្លែង** (ឈ្មោះសត្វស្លាបមួយប្រភេទ សម្បុរក្រហមក្រមៅ ត្រង់កមានសម្បុរ-ស ចំពុះខុប ក្រញាំជើងចំណាប់មាំ អាចចាប់សត្វតូចៗស៊ីបាន)

ខ្លែង មានច្រើនប្រភេទ :

- ខ្លែង កូនមាន់
- ខ្លែង ក្រហម ឬ ខ្លែង ត្រី
- ខ្លែង ខ្មោច
- ខ្លែង ស្រាក

**គគីរ** (ឈ្មោះឈើធំមួយប្រភេទ សាច់រឹងជាប់ សម្រាប់ប្រើធ្វើទូក និងការឯទៀតផ្សេងៗ)

គគីរ មាន២យ៉ាង : (ទំ.១២១)

- គគីរ ថ្ម
- គគីរ ខ្សាច់

**គំនាបត្នោត** (ប្រដាប់សម្រាប់គាប, ឃ្នាប)

គំនាបត្នោត មាន២ប្រភេទ : (ទំ.១៩៦)

- គំនាបត្នោត ឈ្នាល
- គំនាបត្នោត ញី

**គ្រញូង** (ឈ្មោះឈើមួយប្រភេទមានខ្លឹមសម្បុរក្រហមក្រមៅ សាច់ជិតស្អិតរឹងជាប់អង្វែងសម្រាប់ប្រើការធ្វើគ្រឿងចលនវត្ថុផ្សេងៗ)

គ្រញូង មាន២យ៉ាង : (ទំ.១៤៩)

- គ្រញូង ដែក (សម្បុរក្រមៅ)
- គ្រញូង ឈាមមាន់ (សម្បុរភារ៉)

**គ្រំ** (ឈ្មោះខ្យងពួកមួយ)

គ្រំ មាន២ប្រភេទ : (ទំ.១៥៩)

- គ្រំ ពោក (គ្រំធំៗ)
- គ្រំ ចំពុះទា (គ្រំតូចៗ)

**គ្រុន** (ឈ្មោះរោគមានអាការស្រៀវក្តៅ)

គ្រុន មានច្រើនយ៉ាង :

- គ្រុន ផ្កាសាយ
- គ្រុន ក្តៅក្រហាយ
- គ្រុន សន្និ
- គ្រុន ញាក់
- គ្រុន ផ្អែមមាត់
- គ្រុន ចាញ់
- គ្រុន រវើរវាយ
- គ្រុន លោះ

**ឃ្មុំ**

(ឈ្មោះសត្វល្អិតមួយប្រភេទក្នុងពួកភមរជាតិ មានទឹកផ្អែម សំណុសសម្រាប់ធ្វើក្រមួន)

ឃ្មុំ មានច្រើនយ៉ាង : (ទំ.១៦៣)

- ឃ្មុំ ផ្អិត
- ឃ្មុំ ធំ
- ឃ្មុំ ប៉ូកគោ
- ឃ្មុំ ត្រចៀកដំរី

**ឃ្លង់**

(ឈ្មោះរោគកើតអំពីឈាមបណ្តាលចេញមកដល់សាច់ស្បែកខាងក្រៅឱ្យមានសម្បុរជាំស៊ុំៗ)

ឃ្លង់ មានច្រើនប្រភេទ : (ទំ.១៦៣)

- ឃ្លង់ ភ្លើង
- ឃ្លង់ ផេះ
- ឃ្លង់ ល្អៅ
- ឃ្លង់ ដែក

**ឃ្លោក**

(ឈ្មោះវល្លិឡើងទ្រើងជាដំណាំស្រុក មានផ្លែជាបន្លែ)

ឃ្លោក មាន២យ៉ាង : (ទំ.១៦៥)

- ឃ្លោក សាយមៀវ (ផ្លែបែបថ្ងទឹក)
- ឃ្លោក វែង ឬហៅត្រឹមតែ ឃ្លោកៗ (ផ្លែវែងៗ)

**ចង្រិត**

(ឈ្មោះសត្វល្អិតមានស្លាបហើរបាន)

ចង្រិត មាន៣ប្រភេទ : (ទំ.១៧៨)

- ចង្រិត ដូង
- ចង្រិត ដែក
- ចង្រិត ខ្មោច

**ចង្វា** (ឈ្មោះត្រីល្អិតមានស្រកា)

ត្រីចង្វា មាន២ប្រភេទ : (ទំ.១៧៨)

- ត្រីចង្វា មូល
- ត្រីចង្វា ភ្លៀង

**ចង្អេរ**

(ប្រដាប់ត្បាញដោយបន្ទោះឫស្សីសម្រាប់អុំស្រូវ, អុំអង្ករ ឬសម្រាប់ហាលអ្វីៗ)

ចង្អេរ មាន៣ប្រភេទ : (១៧៩)

- ចង្អេរ អុំ
- ចង្អេរ គ្រោង
- ចង្អេរ ក្រឡៅ

**ចាន់ ឬ ច័ន** (ឈ្មោះឈើមានផ្លែកាលនៅខ្ចីមានរសចត់ លុះដល់ទុំមានក្លិនក្រអូបប្រហើរឈ្ងប់ មានរសផ្អែម)

ចាន់ មាន២ប្រភេទ : (ទំ.១៨៣)

- ចាន់ មូល (ផ្លែមូល)
- ចាន់ សំប៉ែត ឬហៅ មាក់ប៉ែន (ផ្លែសំប៉ែតទ្រមៀចៗ)

**ចប**

(ប្រដាប់ធ្វើដោយដែកសម្រាប់កាប់,ចូក,ជីក,ជម្រះដី)

ចប មានច្រើនយ៉ាង : (ទំ.១៨៥)

- ចប កាប់
- ចប ចក់
- ចប ចូក
- ចប ជីក
- ចប ជម្រះ
- ចប ប៉ែល
- ចប ត្រសេះ
- ចប ឆាយ
- ចប ជ្រួយដី
- ចប ស្នែង

**ចាប** (ឈ្មោះបក្សីតូចៗ)

ចាប មានច្រើនប្រភេទ : (ទំ.១៩៣)

- ចាប ចៀបកប្បាស
- ចាប ពូក
- ចាប ស្រុក
- ចាប បំណែកល្ង
- ចាប ចង្រ្កង់
- ចាប ព្រៃ

**ចេក** (ឈ្មោះដំណាំមានស្លឹកប្រើការមានផ្លែជាអាហារ)

ចេក មានច្រើនប្រភេទ : (ទំ.២០១)

- ចេក ណាំវ៉ា
- ចេក អំបូង
- ចេក ធ្នួន
- ចេក ពងមាន់
- ចេក ស្នាប់មុខ

- ចេក ផ្កា
- ចេក ក្រចកអណ្ដើក
- ចេក ឈើទាល
- ចេក តើ្យ
- ចេក ទឹក
- ចេក បាយ
- ចេក ផ្ទៃ
- ចេក ពុំសែន
- ចេក មហាត្រកាល
- ចេក មាស
- ចេក ម្រាមដៃនាង
- ចេក រាជសីហ៍
- ចេក លំក្ត
- ចេក លវ៉ា
- ចេក ស្វែង

**ចំប៉ី** (ឈ្មោះឈើមានជំរ-ស ស្រដៀងនឹងទឹកដោះ ផ្កាក្រអូបឆ្អិត)

ចំប៉ី មាន៣យ៉ាង : (ទំ.២១១)

- ចំប៉ី ក្រហម ឬ ចំប៉ីទេស
- ចំប៉ី ឈើង
- ចំប៉ី ស

**ឆ្កោ** (ឈ្មោះត្រីស្រកាមួយប្រភេទ ពួកត្រីរស់)

ត្រីឆ្កោ មាន៣ប្រភេទ : (ទំ.២៣៦)

- ត្រីដៀប (កាលនៅតូច)
- ត្រីឆ្កោ (ធំល្មម)
- ត្រីរាហូ (ធំមែនទែន)

**ជីរ**

(ឈ្មោះដំណាំមួយពួកសម្រាប់ប្រើស្លឹកជារបោយ ឬបង់បំបាត់ក្លិនឆ្អាប)

ជីរ មានច្រើនប្រភេទ : (ទំ.២៦១)

- ជីរ នាងវង
- ជីរ លីងលាក់
- ជីរ ស្លឹកគ្រៃ
- ជីរ អង្កាម
- ជីរ វ៉ាន់ស៊ុយ
- ជីរ ស
- ជីរ ថ្កាល់ត្រី

**ជ្រូក** (ឈ្មោះសត្វចតុប្បាទមួយប្រភេទ)

ជ្រូក មានច្រើនយ៉ាង : (ទំ.២៧៩)

- ជ្រូក ស្រុក (ចិញ្ចឹមក្នុងស្រុក)
- ជ្រូក ព្រៃ (អាស្រ័យនៅក្នុងព្រៃ)
- ជ្រូក ត្រើប (អាស្រ័យនៅលើត្រើប)
- ជ្រូក ព្រុល (អាស្រ័យនឹងព្រៃស្បាតភ្នំ)

**ជ្រៃ** (ឈ្មោះឈើមានជំរ មានឫសរយីករយាកឬពំនួពំន្ល)

ជ្រៃ មានច្រើនយ៉ាង : (ទំ.២៨០)

- ជ្រៃ ពោធិ

- ជ្រៃ ក្រឹម
- ជ្រៃ ល្បៀប
- ជ្រៃ ត្រាង
- ជ្រៃ រំលិ

## ជំទប់

(មន្ត្រីអ្នកកាន់ការក្នុងសង្កាត់ជាអ្នកជួយទប់ទល់ចៅសង្កាត់នានា ក្នុងប្រទេសកម្ពុជា)

ជំទប់ មាន៣ថ្នាក់ : (ទំ.២៧២)

- ជំទប់ រាជា (ជំទប់លេខ១)
- ជំទប់ សេនា (ជំទប់លេខ២)
- ជំទប់ ភក្តិ (ជំទប់លេខ៣)

## ឈូក (ជលជាតិពួកមួយ

ដើមរឹងមានបន្លា ស្លឹកធំកំពាង ផ្កា ប្រើជាគ្រឿងបូជា ក្រអៅនិងដើមប្រើជាអាហារបាន ច្រើនយ៉ាង)

ឈូក មានច្រើនប្រភេទ : (ទំ.២៨៤)

- ឈូក ស
- ឈូក ក្រហម
- ឈូក ច្រាល
- ឈូក រតន៍
- ឈូក រាត់

## ឈ្នាង (ឈ្មោះប្រដាប់នេសាទមច្ឆជាតិ)

ឈ្នាង មាន៣ប្រភេទ : (ទំ.២៨៧)

- ឈ្នាង ដង
- ឈ្នាង ដៃ ឬ ឈ្នាងជញ្ជាត់
- ឈ្នាង ត្រាំ

## ឈ្មុស

(សត្វជើងបួនពួកសំពោចមានទឹកសុក្កៈឬទឹកកាមក្លិនប្រហើរភាយសម្រាប់លាយផ្សំធ្វើទឹកអប់)

ឈ្មុស មាន២ប្រភេទ : (ទំ.២៨៨)

- ឈ្មុស ស្បូវ
- ឈ្មុស ប្រែង ឬ ឈ្មុសទេស

## ឈ្លើង (សត្វទឹកឥតឆ្អឹង ស្បែកស្វិតយឺតរអិល ទាមជញ្ជក់ឈាមមនុស្ស, សត្វ)

ឈ្លើង មានច្រើនប្រភេទ : (ទំ.២៨៩)

- ឈ្លើង កន្លាស់
- ឈ្លើង ស្រែ
- ឈ្លើង ព្រំត្រ
- ឈ្លើង ក្របី
- ឈ្លើង ដំរី
- ឈ្លើង ម្ជុល
- ឈ្លើង សមុទ្រ

## ញរ

(ឈ្មោះឈើមានផ្លែប្រើជាថ្នាំឬជាអាហារស្លឹកក៏ប្រើជាអាហារបានដែរ)

ញរ មាន២ប្រភេទ : (ទំ.២៩០)

- ញរ ស្រុក
- ញរ ព្រៃ

## ដកខិម

(ឈ្មោះឈើតូចមានផ្កាសម្រាប់ដាំក្នុងផើង ប្រើជាគ្រឿងតាំងឬដាំក្នុងសួន)

ដកខិម មាន៣ប្រភេទ :

(ទំ.២៩៩)

- ដកខិម ក្រហម
- ដកខិម លឿង
- ដកខិម ស

## ដង្កូវ (សត្វល្អិត ពួកសត្វវារ,សត្វលូនឥតជើងខ្លះ មានជើងខ្លះ)

ដង្កូវ មានច្រើនប្រភេទ : (៣០១)

- ដង្កូវ ដីកឧស
- ដង្កូវ ខួង
- ដង្កូវ ទឹក
- ដង្កូវ នាង
- ដង្កូវ បាក់ខ្នង
- ដង្កូវ សាច់

## ដឹង

(ប្រដាប់គ្រឿងប្រើប្រាស់ធ្វើដោយដែកមានដងមានផ្លែសម្រាប់ក្របែល, ពុះ, ចាំងឈើ)

ដឹង មាន៣ប្រភេទ : (ទំ.៣០៧)

- ដឹង ភ្លុក ឬ ដឹងស្លាប
- ដឹង ជង
- ដឹង ផ្កា

## ដូង (ឈើស្រុកមានផ្លែជាអាហារផ្លែមានទឹកមានសាច់ខាងក្នុងរលាកាលណាទុំសាច់នោះមានប្រេង)

ដូង មានច្រើនប្រភេទ :

(ទំ.៣០៨)

- ដូង ផេះ
- ដូង ភ្លើង
- ដូង សៃត
- ដូង ខ្ទិះ
- ដូង តាកែ
- ដូង ត្នោត
- ដូង នាល

## ដំឡូង (វល្លិមានមើមប្រើជាអាហារ)

ដំឡូង មានច្រើនប្រភេទ :

(ទំ.៣២០)

- ដំឡូង ជ្រូក
- ដំឡូង ស្រំ
- ដំឡូង បាស
- ដំឡូង ផ្កា
- ដំឡូង ឈាមមាន់
- ដំឡូង ដូង
- ដំឡូង ដៃខ្លា
- ដំឡូង ត្រែង
- ដំឡូង ទឹក
- ដំឡូង ទៀន
- ដំឡូង ពងប្រវឹក

- ដំឡូង ពស់
- ដំឡូង ស្វា
- ដំឡូង ក្រពើ
- ដំឡូង ជ្រៅ
- ដំឡូង បារាំង
- ដំឡូង ពងលលក
- ដំឡូង ភ្លុក
- ដំឡូង រលួស
- ដំឡូង ភក់

## ត្រសក់ ឬ តាសក់

(ឈ្មោះវល្លិដំណាំមានផ្លែជាអាហារ)

ត្រសក់ មានច្រើនប្រភេទ : (ទំ.៣៥៤)

- ត្រសក់ ស្រូវ
- ត្រសក់ ផ្អែរ
- ត្រសក់ កញ្ច្រៀប
- ត្រសក់ ក្បាលស្វា
- ត្រសក់ ក្អែក
- ត្រសក់ ខ្លូត
- ត្រសក់ ថ្ម
- ត្រសក់ ទ្រើង

## ត្បាល់

(ប្រដាប់សម្រាប់ប្រើការខាងបុក,កិន,ជាន់,បក់,ស្រូវ)

ត្បាល់ មានច្រើនប្រភេទ : (ទំ.៣៥៩)

- ត្បាល់ កិន
- ត្បាល់ ជាន់ ឬ ត្បាល់ភ្លើង
- ត្បាល់ បុក
- ត្បាល់ បក់

## ត្មាត (ឈ្មោះសត្វស្លាបធំបរិភោគសាកអសុភជាអាហារ)

ត្មាត មាន២ប្រភេទ : (ទំ.៣៦០)

- ត្មាត ភ្លើង (មាឧធំមាំក្បាលក្រហមដូចភ្លើង)
- ត្មាត ផេះ (មាឧតូចជាងត្មាតភ្លើងសម្បុរប្រផេះ)

## ត្រប់

(ឈ្មោះដំណាំមានផ្លែបរិភោគជាបន្លែឬអន្លក់)

ត្រប់ មានច្រើនប្រភេទ : (ទំ.៣៦៦)

- ត្រប់ ក្រាមរមាស
- ត្រប់ វែង ឬ ត្រប់សណ្តាយ
- ត្រប់ សំបកស្រួយ ឬ ត្រប់ស្រួយ
- ត្រប់ ពុតលំញង ឬ ត្រប់ចង្កោម
- ត្រប់ ខារ
- ត្រប់ ក្តគោ
- ត្រប់ ហ្លេកគោ
- ត្រប់ ពងមាន់

- ត្រប់ រោម
- ត្រប់ លាវ

**ត្រាច** (ឈ្មោះឈើធំពួកឈើទាលសម្រាប់យកជ័រទឹក ខ្លឹមប្រើការជាប់ធន់ជាងឈើទាល)

ត្រាច មាន២ប្រភេទ : (ទំ.៣៧១)

- ត្រាច ស
- ត្រាច ក្រហម

**ត្រៀល**

(ឈ្មោះឈើព្រៃមានផ្លែប្រើជាអាហារបាន)

ត្រៀល មាន២ប្រភេទ : (ទំ.៣៧៨)

- ត្រៀល ដោះក្របី
- ត្រៀល ស្វា

**ត្រាវ** (ឈ្មោះប្រទាលមួយប្រភេទសណ្ឋានក្ដាតមានធាង មានមើមបរិភោគបាន)

ត្រាវ មានច្រើនប្រភេទ :

- ត្រាវ ក្រមួន
- ត្រាវ គៀប
- ត្រាវ ជើងរមាស
- ត្រាវ ព្រៃ
- ត្រាវ ស្លា

**តាន** (ឈ្មោះរោគមួយប្រភេទ)

តាន មានច្រើនប្រភេទ :

- តាន ត្រី
- តាន ទឹកដោះ
- តាន ភ្លើង
- តាន មាន់

**ទម្លាយរត** (ឈ្មោះប្រទាលផ្ញើប្រាណដុះតោងអាស្រ័យនឹងដើមឈើរស់ ជាថ្នាំរំងាប់រោគផ្សេងៗ តាមទម្លាប់ប្រើ)

ទម្លាយរត មាន២ប្រភេទ : (ទំ.៤១៣)

- ទម្លាយរត ញី
- ទម្លាយរត ឈ្មោល

**ទា**

(ឈ្មោះសត្វស្លាបពួកមួយមានម្រាមជើងជាប់គ្នាស្រដៀងនឹងប្រវឹក)

ទា មាន៣ប្រភេទ : (៤១៧)

- ទា ស្រុក
- ទា កាប៉ា
- ទា ព្រៃ

**ទិស**

(ភាគ,ចំណែកមុខក្រោយឆ្វេងស្តាំព្រមទាំងជ្រុងជាចន្លោះទាំងបួននិងខាងលើខាងក្រោម)

ទិស មាន១០ : (ទំ.៤២៨)

- ទិសធំ ៤
- ទិសតូច ៤
- ទិសបន្ទាប់ ២

**ទីពោ ឬ ត្រីពោ** (ឈ្មោះត្រីរំអិលពួកត្រីប្រា)

ទីពោ មាន២ប្រភេទ : (ទំ.៤៣១)

- ត្រីពោ ព្រុយ
- ត្រីពោ ខ្មៅត្រចៀក

**ទុង** (ឈ្មោះបក្សីពួកមួយ មានរូបសណ្ឋានជមពីមុខពីក្រោយ, កវែង, ចំពុះវែងសំប៉ែត, មានចុងក្ងិច មានស្បែកពីខាងក្រោយសណ្ឋានថង់, ជើងខ្ពស់ម្រាម ជាប់ដូចជើងទា, ហែលទឹកមុជទឹកបាន, ហើរបានខ្ពស់)

ទុង មាន២ប្រភេទ : (ទំ.៤៣៨)

- ទុង សំពៅ
- ទុង ផេះ

**ទៀប** (ឈ្មោះឈើដំណាំ ពួកមាក់បាត ជាដំណាំមានដើមទាបៗ

ល្មមបេះផ្លែបានដោយងាយ,ផ្លែទុំប្រើជាបង្អែម ស្រស់)

ទៀប មានច្រើនប្រភេទ : (ទំ.៤៤៧)

- ទៀប បាយ ឬ ទៀបសាច់ជ្រាយ
- ទៀប ស្វិត ឬ ទៀបសាច់ស្វិត
- ទៀប បន្លា ឬ ទៀបទេស ឬ ទៀបបារាំង

**ទ្រ**

(ឈ្មោះគ្រឿងភ្លេងខ្សែពួកមួយប្រើខាងកូតឱ្យឮសូរសព្ទ)

ទ្រ មានច្រើនប្រភេទ : (ទំ.៤៦១)

- ទ្រ ខ្មែរ
- ទ្រ អ៊ូ
- ទ្រ ឆេ
- ទ្រ សោ

**ទ្រៀល ឬ ត្រៀល**

(ឈ្មោះឈើតូចនិងវល្លិដើមរឹង)

ទ្រៀល មាន២ប្រភេទ : (ទំ.៤៦៨)

- ទ្រៀល ស្វា
- ទ្រៀល ដោះក្របី

**ទៀន**

(គ្រឿងសម្រាប់អុជធ្វើដោយក្រមួនឬខ្លាញ់មានអំបោះជាប្រឆេះ សម្រាប់អុជយកពន្លឺជាសក្ការបូជា ឬប្រើអុជបំភ្លឺតាមធម្មតា)

ទៀន មានច្រើនប្រភេទ :

- ទៀន កល្ប
- ទៀន គោល
- ទៀន ជ័យ
- ទៀន វស្សា

**ទន្សាយ** (ឈ្មោះសត្វតូចជើងបួន មិនផឹកទឹក ផឹកតែសន្សើម)

ទន្សាយ មាន២ប្រភេទ :

- ទន្សាយ គល់
- ទន្សាយ ស្លឹក

**ននោង** (ឈ្មោះវល្លិដំណាំឡើងទ្រើង មានផ្លែជាអាហារ)

នគោង មានច្រើនប្រភេទ : (ទំ.៥៩៥)

- នគោង ជ្រុង
- នគោង ទេស
- នគោង សាញ

## បបែល ឬ ប្របែល

(ឈ្មោះមច្ឆជាតិពួកមួយមានរូបមូល នៅមាត់ខាងក្រោមមានដាយគ្រែងជុំវិញ កន្ទុយវែង ស្បែករឹងគគ្រាត, បើស្ងួត ក្រៀមប្រើការរូសឈើបាន)

បបែល មានច្រើនប្រភេទ : (ទំ.៥៥២)

- បបែល កូនមាន់
- បបែល ភ្នែកលៀន
- បបែល រុយ
- បបែល ត្រី
- បបែល ទង់
- បបែល អក
- បបែល ខ្លែង
- បបែល ខ្លា
- បបែល ក្របី
- បបែល រលួស
- បបែល ស្លឹក
- បបែល ខ្យល់
- បបែល សេះ
- បបែល គ្រោក
- បបែល ភក់

## បបរ (អាហាររាវធ្វើដោយអង្ករស្ងោរ)

បបរ មានឈ្មោះច្រើនយ៉ាង : (ទំ.៥៥២)

- បបរ ស
- បបរ គ្រឿង
- បបរ ប្រុង
- បបរ ឈ្មោល

## បាយម៉ាត (ឈ្មោះឈើតូចមួយប្រភេទ ស្លឹកមានក្លិនក្រអូបប្រហើរ)

បាយម៉ាត មាន២ប្រភេទ : (ទំ.៥៦៦)

- បាយម៉ាត ស្រុក
- បាយម៉ាត ព្រៃ

## បូស

(ឈ្មោះរោគហើមសាច់ពង់ដោរកជាខ្ទុះ-ស ឬ ខ្ទុះខ្ទរអណ្តែង)

បូស មានច្រើនប្រភេទ : (ទំ.៥៨៦)

- បូស ធំ
- បូស ទ្រនិច
- បូស ក្រពើ
- បូស ផ្កាប់មុខ
- បូស ក្រាល
- បូស ស្វាយ

## បំពួនស្អារ (ឈ្មោះនំស្រស់មួយប្រភេទ ធ្វើដោយម្សៅដំណើបលញ់ស្រោបបំពួនជុំស្ករត្នោត បំបាំងបាត់មើលមិនឃើញ)

នំនេះ មានឈ្មោះហៅបានច្រើនយ៉ាង : (ទំ.៥៩៨)

- នំ បំពួនស្គរ
- នំ ផ្លែអាយ
- នំ កើតក្ដី
- នំ បង្គប់ស្គរ

## បាតុកម្ម

(ការធ្វើឱ្យដឹងឬឱ្យឃើញប្រាកដ,ការលើកគ្នាដង្ហែជាក្បួន ដើម្បីសម្ដែងសេចក្ដីមិនពេញចិត្តចំពោះអំពើអ្វីនីមួយឬ ទទូចសុំស្រុះគ្នាឱ្យសម្រេចផលប្រយោជន៍អ្វីមួយតាមសេចក្ដីពេញចិត្តខ្លួនទាំងអស់គ្នា)

បាតុកម្ម មាន៣ប្រភេទ : (ទំ.៦២៦)

- បាតុកម្ម បំពានច្បាប់
- បាតុកម្ម ឡើងចាង
- បាតុកម្ម សុភាព

## បុថុជ្ជន

(ជនមានកិលេសក្រាស់,សត្វលោកក្រៅពីអរិយបុគ្គលទាំង៨ពួក)

បុថុជ្ជន មានច្រើនប្រភេទ : (ទំ.៦៣០)

- កល្យាណ បុថុជ្ជន
- បាប បុថុជ្ជន
- បណ្ឌិត បុថុជ្ជន
- ពាល បុថុជ្ជន

## ប្រកាំង

(ឈ្មោះរោគបណ្ដាលឱ្យឈឺក្បាលចាប់ពើតខ្មោកៗ)

ប្រកាំង មាន២ប្រភេទ : (ទំ.៦៤១)

- ប្រកាំង បាយកក ឬ ប្រកាំងតូច
- ប្រកាំង ដី ឬ ប្រកាំងធំ

## ប្រដេញ

(ឈ្មោះឈើតូច ស្លឹកល្អិតស្រយ៉ៀងនឹងស្លឹកអំពិល មានផ្កាផ្លែចេញពីស្លឹក)

ប្រផេញ មាន២ប្រភេទ : (ទំ.៦៥៥)

- ប្រផេញ ញី (មានផ្កាសម្បុរ-ស)
- ប្រផេញ ឈ្មោល (មានផ្កាក្រហម)

## ប្រយុទ្ធ

(ឈ្មោះឈើតូចពួកមួយមានផ្កាជាចង្កោមកម្រងល្អិតៗ សម្បុរលឿង ក្លិនក្រអូបឆ្ងាញ់ប៉ុន្តែក្រអូបស្មើយ)

ប្រយុង្គ មាន២ប្រភេទ : (ទំ.៦៦២)

- ប្រយុង្គ ធំ
- ប្រយុង្គ តូច

## ប្រមេះ

(ឈ្មោះរោគពិការទឹកមូត្រគឺរោគដែលបណ្ដាលឱ្យកើតជាខ្ទុះឬ

កកើតជាគ្រាប់រឹងខាំងរាំងបស្សាវមគ្គ
ឱ្យលំបាកបន្ទោបស្សាវៈ)

ប្រមេះ មាន២ប្រភេទ :
(ទំ.៦៦២)

- ប្រមេះ ទឹកបាយ
- ប្រមេះ គ្រាប់

**ប្រាជ្ញ** (អ្នកមានប្រាជ្ញា , អ្នកចេះ)

ប្រាជ្ញ មានច្រើនយ៉ាង : (ទំ.៦៧៦)

- ប្រាជ្ញ មានមារយាទ
- ប្រាជ្ញ ឥតមារយាទ
- ប្រាជ្ញ ក្រោក ឬ ក្រោកប្រាជ្ញ
- ប្រាជ្ញ ក្នុង ឬ ប្រាជ្ញគំនិត
- ប្រាជ្ញ សម្តី

**បង្កង** (សត្វដែលមានឆ្អឹងជាស្បែកពួកមួយ
មានជើងវែងៗ,មានតង្កៀប,
មានព្រុយត្រង់ពោះ, ក្បាលស្រួច,
មានពុកមាត់វែងរឹងហៅថា
ពុកបង្កង,ជាសត្វកើតនៅក្នុងទឹកសាបក៏មាន
នៅក្នុងទឹកប្រៃក៏មាន)

បង្កង មានច្រើនប្រភេទ :

- បង្កង ព្រៃាន
- បង្កង សមុទ្រ
- បង្កង សៅទារ

**ប្រពាយ** (ឈ្មោះវល្លិដំណាំមួយប្រភេទ
ផ្លែប្រើជាអន្លក់,បន្លែ)

ប្រពាយ មានច្រើនយ៉ាង :

- ប្រពាយ ក្រចក
- ប្រពាយ ជ្រុង
- ប្រពាយ លាក់
- ប្រពាយ ស្បែក

**ផ្ដៅ**

(ឈ្មោះវល្លិដើមរឹងមួយប្រភេទមានបន្លានៅស្រទ
ប,ធាង,ស្លឹក)

ផ្ដៅ មានឈ្មោះច្រើនយ៉ាង :
(ទំ.៧០៨)

- ផ្ដៅ ទឹក
- ផ្ដៅ ក្រែក
- ផ្ដៅ ឈ្វាំង
- ផ្ដៅ អារ៉ែច
- ផ្ដៅ ដំបង
- ផ្ដៅ ថ្នល់
- ផ្ដៅ រពាក់
- ផ្ដៅ សំ
- ផ្ដៅ ស្វា

**ផ្ទី** (ឈ្មោះស្មៅពួកមួយ មានបន្លាខ្លះ
ឥតបន្លាខ្លះ)

ផ្ទី មានច្រើនប្រភេទ : (ទំ.៧១០)

- ផ្ទី បន្លា
- ផ្ទី អាចម៍មាន់
- ផ្ទី ថ្ម

## ផ្លិត

(ប្រដាប់សម្រាប់បក់ឱ្យកើតខ្យល់ឬសម្រាប់កាន់បាំងក្នុងវេលាសូត្រធម៌ឬទេស្នា)

ផ្លិត មានឈ្មោះច្រើនយ៉ាង :

(ទំ.៧១៣)

- ផ្លិត ដៃ
- ផ្លិត ស្លាបសត្វ
- ផ្លិត ស្លឹកត្នោត
- ផ្លិត ដងខ្លី
- ផ្លិត ដងវែង
- ផ្លិត មុខព្រហ្ម
- ផ្លិត ងយ
- ផ្លិត ទាញ
- ផ្លិត ចាមរ

## ផ្សិត

(ភូតគ្រាមមួយពួកដុះទុលចេញពីក្នុងដីសើមឬដុះពីក្នុងទីអាប់អួរ ឬដុះនៅឈើពុកជាដើម មានសណ្ឋានផ្សេងៗគ្នា ខ្លះសម្រាប់បរិភោគបាន ខ្លះសម្រាប់ប្រើធ្វើថ្នាំរំងាប់រោគ ខ្លះពុល)

ផ្សិត មានឈ្មោះច្រើនយ៉ាង :

(ទំ.៧១៦), (ទំ.១៤៨៧)

- ផ្សិត កញ្ជេរ
- ផ្សិត ក្រាមរមាស
- ផ្សិត ខ្សាច់
- ផ្សិត ចុងអង្ករ
- ផ្សិត ចេក
- ផ្សិត ចំបើង
- ផ្សិត ត្រចៀកកណ្ដុរ
- ផ្សិត ស្នាច់
- ផ្សិត សណ្ដែក
- ផ្សិត ឫស្សី
- ផ្សិត ក្រកោះ
- ផ្សិត ត្រាច
- ផ្សិត ស្វក្រំ
- ផ្សិត ក្បាលថ្លែន
- ផ្សិត ពពារនាគរាជ
- ផ្សិត ស្រែះ (ពុល)
- ផ្សិត ចំពុះសេក

## ផ្កាយ

(ពន្លឺច្រើនដួងក្រៅពីព្រះចន្ទដែលមើលទៅឃើញព្រាតឯអាកាសក្នុងវេលាយប់)

ផ្កាយ មានច្រើនយ៉ាង :

- ផ្កាយ កូនមាន់
- ផ្កាយ ក្រពើ
- ផ្កាយ ដុះកន្ទុយ
- ផ្កាយ ព្រឹក
- ផ្កាយ ព្រះគ្រោះ
- ផ្កាយ មេរុ
- ផ្កាយ យាម
- ផ្កាយ ល្ងាច
- ផ្កាយ សុក្រ

**ពព្លាក់** (ឈ្មោះពស់ពួកមួយមានពិសខ្លាំង)

ពស់ពព្លាក់ មាន២ប្រភេទ :

(ទំ.៧៣៥)

- ពស់ពព្លាក់ វល្លិ
- ពស់ពព្លាក់ រំហោក

**ពស់** (សត្វពួកទីឃជាតិអាសីរពិសផ្សេងៗ)

ពស់ មានច្រើនប្រភេទ :

(ទំ.៧៤០)

- ពស់ វែករនាម
- ពស់ វែកដំបូក
- ពស់ វែកស្រងែ
- ពស់ ក្រាយ
- ពស់ ពព្លាក់
- ពស់ សង់ស៊ើ
- ពស់ ព្រៃ
- ពស់ ទងត្នោត
- ពស់ ព្រលឹត
- ពស់ សម្លាប់កង្កែប
- ពស់ វែកក្របី
- ពស់ រំកាច់មាស
- ពស់ វែកកង្កែប
- ពស់ ក្បាលពីរ
- ពស់ ក្រចាន់តាមម
- ពស់ ខ្សែតោ
- ពស់ ជើង
- ពស់ ដែកចារ
- ពស់ ត្រី
- ពស់ ថ្លាន់
- ពស់ ធាងត្នោត
- ពស់ នាគរាជ
- ពស់ ប្រមោយដឹរ
- ពស់ ពព្លាក់វល្លិ
- ពស់ ពព្លាក់រំហោក
- ពស់ ភ្លើង
- ពស់ ឥតភ្នែក

**ពោត**

(ឈ្មោះដំណាំពួកមួយរាប់បញ្ចូលក្នុងធញ្ញជាតិ)

ពោត មានច្រើនប្រភេទ :

(ទំ.៧៧៨)

- ពោត ក្លាត
- ពោត ក្រហម
- ពោត ខ្សាយ
- ពោត ជក់
- ពោត ដំណើប
- ពោត ភ្លុង
- ពោត លំខ
- ពោត ស

**ពោធិ៍** (ឈ្មោះឈើពួកមួយ

ស្លឹកហាងប្រហើរ,ផ្លែមានជំរស្អិតនៅ

រុំគ្រាប់ កាលនៅខ្ចីមានរសហាង

លុះដល់ធំឡើងសម្បុរ

លឿងមានក្លិនក្រអូបឈ្ងុយ)

ព្នៅ មាន២ប្រភេទ : (ទំ.៧៨៥)

- ព្នៅ ពងមាន់
- ព្នៅ សណ្តាយ

## ព្រីង (ឈ្មោះឈើមួយប្រភេទ មានផ្លែប្រើជាអាហារ)

ព្រីង មានច្រើនយ៉ាង : (ទំ.៨០០)

- ព្រីង ចន្ទន៍
- ព្រីង ចន្ទុះ
- ព្រីង ដោះក្របី
- ព្រីង បាយ

## ភ្នំ

(ពំនូកដីឬថ្មខ្ពស់ត្រដែតផុតឡើងពីផ្ទៃដីប្រក្រតីដែលនៅជិតខាង)

ភ្នំ មាន៣ប្រភេទ : (ទំ.៨៣៣)

- ភ្នំ ដីសុទ្ធ
- ភ្នំ ថ្មសុទ្ធ
- ភ្នំ លាយថ្មនិងដី

## ភ្លូង

(ឈ្មោះឈើព្រៃមួយប្រភេទមានសាច់រឹងស្អិទ្ធ)

ភ្លូង មាន២ប្រភេទ : (ទំ.៨៣៥)

- ភ្លូង ជូរ
- ភ្លូង ក្អែក

## មាន់ (សត្វទ្វិបាទមួយប្រភេទជាជាតិបក្សី តែហើរបានដោយខ្សោយ)

មាន់ មានច្រើនប្រភេទ : (ទំ.៨៨១)

- មាន់ កណ្តូង ឬ មាន់នាឡ
- មាន់ ក្រញាស
- មាន់ គក
- មាន់ គ្រេវ
- មាន់ ចៃ
- មាន់ ទាង
- មាន់ ទឹក
- មាន់ ទេស
- មាន់ បារាំង
- មាន់ ព្រៃ
- មាន់ ស្រុក

## មៀន (ឈ្មោះឈើមួយប្រភេទ ផ្លែមូលៗទំហំខ្នាតមេដៃ រលាទុំ មានក្លិនសាច់ក្រអូប មានរសផ្អែម)

មៀន មាន២ប្រភេទ : (ទំ.៩០៦)

- មៀន ព្រៃ
- មៀន អំបុក

## ម៉ៃសាក់ ឬ ម៉ៃស័ក

(ឈ្មោះឈើធំមួយប្រភែទមានសាច់ ជាប់ប្រើការធន់បានយូរ)

ម៉ៃសាក់ មាន៣ប្រភេទ : (ទំ.៩១៤)

- ម៉ៃសាក់ ដែក
- ម៉ៃសាក់ មាស
- ម៉ៃសាក់ អាចម៍ក្របី

**ម្កាក់** (ឈ្មោះឈើមួយប្រភេទ ស្លឹកខ្ចីនិងផ្លែមានរសជូរឆ្ងាញ់)

ម្កាក់ មាន២ប្រភេទ : (ទំ.៩១៨)

- ម្កាក់ ព្រៃ
- ម្កាក់ ស្រុក ឬ ម្កាក់បារាំង

**ម្ជុល ឬ អំបោះ**

(គ្រឿងដេរធ្វើដោយដែក មានរូបមូលតូចចុងស្រួច ត្រង់គល់មានប្រហោងសម្រាប់ដោតចេស)

ម្ជុល មានច្រើនប្រភេទ : (ទំ.៩១៩)

- ម្ជុល ក្តោង
- ម្ជុល ខ្វាស់
- ម្ជុល ដេរ
- ម្ជុល បារាំង

**ម្ទេស** (ឈ្មោះឈើដំណាំមួយប្រភេទ ដើមតូចៗទាបៗផ្លែប្រើជាគ្រឿងហឹរ)

ម្ទេស មានច្រើនប្រភេទ : (ទំ.៩២០)

- ម្ទេស ខ្មាំង
- ម្ទេស ផ្លោក ឬ ម្ទេសសំពៅ
- ម្ទេស លំក
- ម្ទេស ដៃនាង
- ម្ទេស ក្តន្ទា
- ម្ទេស ស្បែង

**ម្នាស់** (ឈ្មោះដំណាំមួយពួក ស្លឹកមានបន្លាសណ្ឋានស្រដៀងនឹងស្លឹករំចេក ផ្លែមានក្រឡាដេរដាសជុំវិញ)

ម្នាស់ មានច្រើនប្រភេទ : (ទំ.៩២១)

- ម្នាស់ ប្រាសាទ
- ម្នាស់ ឃ្មុំ ឬ ម្នាស់ខម
- ម្នាស់ សំពៅ

**ម្រេច**

(ឈ្មោះដំណាំឡើងជន្លង់មួយប្រភេទ ដើមនិងស្លឹកស្រដៀងនឹងម្លូ តែស្លឹកតូចក្រាស់រឹងជាងម្លូ គ្រាប់មូលៗល្អិតៗប្រើជាគ្រឿងផ្សំម្ហូប ឬជាថ្នាំក្តៅ)

ម្រេច មានច្រើនប្រភេទ : (ទំ.៩២៣)

- ម្រេច ស ឬ ម្រេចកោរ
- ម្រេច ខ្មៅ
- ម្រេច ទន្សាយ
- ម្រេច អាចម៍សត្វ

**ម្រះ**

(ឈ្មោះវល្លិដំណាំឡើងទ្រើងមួយប្រភេទ មានស្លឹកឆែកៗ ផ្លែមានពករម៉ិងរម៉ង់)

ម្រះ មាន២ប្រភេទ : (ទំ.៩២៤)

- ម្រះ ទេស
- ម្រះ ភ្លុក

## ទ្រម្រាម

(ឈ្មោះភមរជាតិពួកមួយស្រដៀងនឹងឃ្មុំ តែតូចៗមិនចេះទិចទេព្រោះគ្មានទ្រនិច ចេះតែខាងរោមខាំបន្តិចៗ

ត្រឹបយកទឹកដមនិងលំអងផ្កាដូចឃ្មុំ តែធ្វើសំបុកនៅក្នុងរន្ធឈើ មានទឹកផ្អែមឈ្ងុយ មានក្រមួនព័ណ៌ខ្មៅហៅថា ជ័រម្រោម)

ម្រោម មាន២យ៉ាង : (ទំ.៩២៤)

- ម្រោម ខ្យាយ ឬ ម្រោមតូច
- ម្រោម ដំណើប ឬ ម្រោមធំ

## ទ្រម្រញ

(ឈ្មោះរោគពួកមួយ ច្រើនតែចាប់កើតត្រង់ក ជារោគរឹងត្អឹង រក្សាឱ្យជាបានដោយកម្រណាស់)

ម្រេញ មានច្រើនប្រភេទ : (ទំ.៩២៤)

- ម្រេញ ក្រាប់
- ម្រេញ ទន្សាយ
- ម្រេញ ទាម
- ម្រេញ ទឹក
- ម្រេញ បណ្ដើរកូន
- ម្រេញ បែក
- ម្រេញ ភ្លើង

## ម្លិះ

(ឈើតូចពួកមួយ ផ្កាសម្បុរ-ស ក្លិនក្រអូបត្រជាក់)

ម្លិះ មាន២យ៉ាង : (ទំ.៩២៥)

- ម្លិះ រួត
- ម្លិះ លា

## ម្អម

(តិណជាតិពួកមួយដុះក្នុងទឹករាក់ឬនៅដីសើមតាមទំនាប

ឬវាលស្រែដោយអន្លើៗ)

ម្អម មាន៣ប្រភេទ : (ទំ.៩២៧)

- ម្អម ខ្សែវ
- ម្អម ក្រហម
- ម្អម ក្ដាម

## យំ

(បញ្ចេញសូរសព្ទព្រមទាំងចេញទឹកភ្នែកព្រោះសេចក្ដីសោកស្ដាយអាល័យ ឬព្រោះមានទោមនស្សអាក់អន់ចិត្ត ឬក៏ព្រោះឈឺចាប់ខ្លាំង)

យំ មានច្រើនប្រភេទ : (ទំ.៩៦០)

- យំ គោក ឬ យំស្ងួត
- យំ គាំង
- យំ ចុងជើង
- យំ ទារ
- យំ ទួញ
- យំ យប់
- យំ យាម
- យំ យែក
- យំ រហាម
- យំ រំងាស់
- យំ លំបាំ ឬ យំរំអុក

- យំ រ៉ាំរ៉ៃ
- យំ សោក
- យំ អណ្តឹតអណ្តក់

**រនាវ** (បន្ទះដែកសំប៉ែតស្តើងមានធ្មេញ មានគ្រឿងភ្ជាប់សម្រាប់កាន់ ជាប្រដាប់សម្រាប់អារឈើ)

រណារ មានច្រើនប្រភេទ : (ទំ.៩៧៧)

- រណារ កន្ទុយត្រី
- រណារ កាត់
- រណារ ច្រៀក
- រណារ យក្ស
- រណារ រ៉

**រនាត** (គ្រឿងភ្លេងវាយដំ មានស្នូករែង មានផ្ទៃធ្វើដោយបន្ទះឫស្សីបន្ទះឈើខ្លឹមរឹងស្រួយ, បន្ទះដែក វាយដោយអន្លូងមួយគូ, ប្រើក្នុងវង់ពិណពាទ្យ)

រនាត មាន៣យ៉ាង : (ទំ.៩៨៨)

- រនាត ឯក
- រនាត ដែក
- រនាត ធុង

**រទេះ** (យានមានកង់សម្រាប់ទឹមគោ, ទឹមក្របីឬប្រើអូស រុញក៏បាន)

រទេះ មានច្រើនប្រភេទ : (ទំ.៩៨៧)

- រទេះ ក្រង់
- រទេះ ក្របី
- រទេះ គោ
- រទេះ ចាម
- រទេះ ជើងគុល
- រទេះ ដឹក ឬ រទេះបន្ទុក
- រទេះ ដែក
- រទេះ ត្រដួស
- រទេះ បំបោល
- រទេះ ផ្ទុរ ឬ រទេះដំបូល
- រទេះ ភ្លើង
- រទេះ ម៉ឺនដា
- រទេះ រុញ
- រទេះ លាត
- រទេះ វាល
- រទេះ សាឡី
- រទេះ សេះ
- រទេះ សំឡី
- រទេះ អូស
- រទេះ ឡាន

**រលក**

(រំជួលទឹកដែលខ្ពួលៗឡើងឬពោរពូនឡើងសោយអំណាចកម្លាំងខ្យល់)

រលក មានច្រើនប្រភេទ : (ទំ.១០០៨)

- រលក ដកពពារ
- រលក ដោះក្រមុំ
- រលក បែកផ្កាត្រែង

- រលក យោល
- រលក រងដំឡូង

**រុយ** (សុខុមសត្វមួយប្រភេទ មានស្លាបហើរបាន ចូលចិត្តរោម អសោច)

រុយ មានច្រើនប្រភេទ : (ទំ.១០៥៦)

- រុយ ខៀវ
- រុយ ដង្កូវ
- រុយ បាយ
- រុយ ស្វា
- រុយ បៃង

**រមៀត** ឬ **ល្មៀត** (ឈ្មោះប្រទាលមួយប្រភេទមានក្លិនប្រហើរ)

រមៀត មានច្រើនប្រភេទ : (ទំ.១០០៣)

- រមៀត សម្ល
- រមៀត ក្រចកអក
- រមៀត សំពៅ
- រមៀត មាស
- រមៀត ស្បង់

**រនាស់** (ប្រដាប់មានមេដង ធ្មេញ សម្រាប់ប្រើការរាស់)

រនាស់ មានច្រើនប្រភេទ : (ទំ.៩៨៩)

- រនាស់ ក្របី
- រនាស់ គោ
- រនាស់ ដៃ

**រលឹម** (តំណក់ភ្លៀងល្អិតៗស្រាលៗ)

រលឹម មានច្រើនប្រភេទ : (ទំ.១០១២)

- រលឹម តូច ឬ រលឹមត្រជាក់
- រលឹម ធំ
- រលឹម ប៉ប្រុយ
- រលឹម ពព្រិច
- រលឹម រោយស្បៃ

**រលួស** (ឈើមួយប្រភេទពួកអសារកព្រឹក្ស)

រលួស មាន៣ប្រភេទ : (ទំ.១០១៣)

- រលួស ផ្អុង
- រលួស ព្រៃ
- រលួស បាយ

**រៃ** (សុខុមសត្វមួយប្រភេទ មានស្លាប,នៅអាស្រ័យនឹងដើមឈើ ខ្ពស់ៗ,យំបញ្ចេញសូរសព្ទឮហួសមាត្រ)

រៃ មាន២ប្រភេទ : (ទំ.១០៦៧)

- រៃ បាយ ឬ រៃចង្រង់
- រៃ កណ្ដឹង

**រាក់** (ឈ្មោះឈើតូច ស្លឹកក្រាស់ សម្បុរ-សប្រផេះ ដែលយ៉ាង

ធំប៉ុនៗបាតដៃ មានជរ- ស)

ដើមរាក់ មាន២ប្រភេទ : (ទំ.១០៣៣)

- រាក់ ស
- រាក់ ក្រហម

**រុន** (កក់មួយប្រភេទ ដើមមូល ស្លឹកធំៗ សំបកឬខ្លួនមានប្រយោជន៍ ប្រើការធ្វើជាខ្ទួច ឬត្បាញធ្វើកន្ទេលជាដើម)

រុន មាន២ប្រភេទ : (ទំ.១០៥៦)

- រុន ទឹក
- រុន ភ្នំ

**រើម** (ឈ្មោះរោគកើតនៅស្បែក ឡើងពងផែរ)

រើម មាន២ប្រភេទ : (ទំ.១០៦១)

- រើម ខ្សាច់ ឬ រើមអង្កាម
- រើម ដឺរ ឬ រើមធំ

**រោក ឬ រោគ** (ឈ្មោះឈើតូច ដើមស្ទើរជាវល្លិ ច្រើនដុះលើដំបូក)

រោក មាន២ប្រភេទ : (ទំ.១០៦៩)

- រោក ស
- រោក ក្រហម

**រំដេញ** (ឈ្មោះឈើរនាម)

រំដេញ មាន២ប្រភេទ : (ទំ.១០៧៥)

- រំដេញ ក្អែក
- រំដេញ ភ្លុក

**រំដេង** (ឈ្មោះប្រទាលពួកក្រកោ)

រំដេង មាន២ប្រភេទ : (ទំ.១០៧៥)

- រំដេង សម្ល
- រំដេង ខ្មៅ

**រាំង** (ឈ្មោះឈើ)

រាំង មាន២ប្រភេទ : (ទំ.១០៨០)

- រាំង ភ្នំ
- រាំង អន្លក់

**ល្វា** (ឈ្មោះឈើមួយប្រភេទ ចេញផ្លែស្អះតាមដើមតាមមែក ឥតផ្កាទេ ចេញជាផ្លែស្រេចមកតែម្តង)

ល្វា មាន៣ប្រភេទ : (ទំ.១១៤២)

- ល្វា ដី
- ល្វា មមង់
- ល្វា តូច ឬ ឧទុម្ពរ

**ល្ហុង** (ឈ្មោះដំណាំមួយប្រភេទ មានផ្កាផ្លែចេញតាមគល់ធាងខ្ចី)

ល្ហុង មានច្រើនប្រភេទ : (ទំ.១១៤៤)

- ល្ហុង ស៊ីផ្លែ
- ល្ហុង ខ្វៃ
- ល្ហុង ខ្វង

**ល្អូត** (បក្សីមួយប្រភេទ)

ល្អូត មាន២ប្រភេទ : (ទំ.១១៤៦)

- ល្ហុត តូក ឬ ល្ហុតធំ
- ល្ហុត ស្វាវ

**លលក** (ឈ្មោះបក្សីមួយប្រភេទ ពួកទទា,ឈ្មោលចេះរងាវ)

លលក មាន២ប្រភេទ : (ទំ.១០៩៥)

- លលក ខ្មោច
- លលក ទ្រាំង

**ល្ហុត** (ឈ្មោះឈើដំណាំ ប្រើផ្លែទុំជាអាហារ)

ល្ហុត មាន៣ប្រភេទ : (ទំ.១១៥០)

- ល្ហុត ខ្មែរ
- ល្ហុត សៃដា ឬ ល្ហុតសៀម
- ល្ហុត ទេស ឬ ល្ហុតបារាំង

**លៀប** (ឈ្មោះឈើពួកជ្រៃ)

លៀប មាន២ប្រភេទ : (ទំ.១១១៥)

- លៀប ធំ
- លៀប តូច

**លាយ**

(ឈ្មោះឧបករណ៍ធ្វើដោយបន្ទោះឬឫស្សីក្រងរាងតូចវែងមាត់រីកកំពោង ឥតប្រឹស ឥតសន្ទះចងក្របួចតូទ)

លាយ មាន២ប្រភេទ : (ទំ.១១០២)

- លាយ ក្រង
- លាយ រូត

**សណ្តែក**

(ដំណាំលតាជាតិដែលដាំយកផ្លែ យកគ្រាប់)

សណ្តែក មានច្រើនប្រភេទ : (ទំ.១២៥២)

- សណ្តែក កង់
- សណ្តែក ទ្រើង
- សណ្តែក បាយ
- សណ្តែក ពួង
- សណ្តែក រាជមាស
- សណ្តែក សៀង
- សណ្តែក អង្គុយ
- សណ្តែក ដី
- សណ្តែក ខ្មៅ
- សណ្តែក ជ្រុង
- សណ្តែក ឆ្វារ
- សណ្តែក ទេស
- សណ្តែក ជន្លង

**សន្ទូច**

(ឈ្មោះឧបករណ៍សម្រាប់ស្ទូចត្រីឬអន្ទង់)

សន្ទូច មាន៣ប្រភេទ : (ទំ.១២៦១)

- សន្ទូច វ៉ាត់
- សន្ទូច រនង
- សន្ទូច អន្ទង់

**សម៉** (ឈ្មោះឈើព្រៃ ផ្លែមានរសល្វីង,ប្រើជាថ្នាំបញ្ចុះឬប្រើបរិភោគផ្ទាប់នឹងផ្អកត្រីប្រៃក៏បាន)

សម៉ មានឈ្មោះច្រើនយ៉ាង : (ទំ.១២៧៤)

- សម៉ ក្អែក
- សម៉ ភ្លុក
- សម៉ ពិភេក

**សំបួរ** (ឈ្មោះឈើពួកមួយ)

សំបួរ មាន៣ប្រភេទ : (ទំ.១២៩៣)

- សំបួរ កក់
- សំបួរ ទេស ឬ សំបួរប្រាក់
- សំបួរ មាស

**សារាយ** (រុក្ខជាតិមួយប្រភេទ ដើមល្អិតៗសែមម៉ៃ ដុះក្នុងទឹកបឹង, ត្រពាំងឬដុះនៅថ្មក្នុងសមុទ្រ)

សារាយ មាន៣ប្រភេទ : (ទំ.១៣៣៩)

- សារាយ ភ្លុក
- សារាយ ជើងមាន់
- សារាយ អំបោះ ឬ សារាយសំង្វ
- សារាយ ថ្ម
- សារាយ បឹង
- សារាយ ពោះក្របី

**សារិកា ឬ សាលិកា** (ឈ្មោះបក្សីមួយពួក)

សារិកា មាន៣ប្រភេទ : (ទំ.១៣៤០)

- សារិកា កែវ ឬ សារិកាឱឡុង
- សារិកា ក្របី
- សារិកា ឱម៉ៃ

**សី** (ប្រដាប់សម្រាប់ទាត់លេងរបស់ពួកបុរស)

សី មានច្រើនប្រភេទ : (ទំ.១៣៥៦)

- សី មេលោង
- សី ដក់
- សី ពែន
- សី ទាត់
- សី វាយ

**សេក** (បក្សីមួយពួក សម្បុរបៃតង ចំពុះខ្លីខុប)

សេក មាន៣ប្រភេទ : (ទំ.១៣៩៨)

- សេក សោម
- សេក យារ
- សេក អាត់ ឬ សេកក្រិស

**សំពោច** (សត្វចតុប្បាទពួកឈ្មុស មានក្លិនសាធុំប្រហើរ)

សំពោច មានច្រើនប្រភេទ : (ទំ.១៤២៣)

- សំពោច ដំណើប

- សំពោច ខ្សាយ
- សំពោច ក្រអូប
- សំពោច ព្រៃង
- សំពោច ស្បូវ

**ស្ពុះ** (វត្ថុមានរសផ្អែម)

ស្ករ មានច្រើនប្រភេទ : (ទំ.១៤៣០)

- ស្ករ ក្រាម
- ស្ករ អំពៅ
- ស្ករ ដូង
- ស្ករ ត្នោត
- ស្ករ ទន្សែ

**ស្គន់** (វល្លិទឹកមួយពួក សន្តានព្រលឹត តែដើមតូចៗ មានខ្លះប្រើជាបន្លែឬអន្លក់បាន)

ស្គន់ មានច្រើនប្រភេទ : (ទំ.១៤៣២)

- ស្គន់ ដំរី
- ស្គន់ ស្គុះ
- ស្គន់ អំបោះ
- ស្គន់ ជើងមាន់

**ស្គរ** (គ្រឿងទូងវាយដំឱ្យលាន់ឮសូររំពង ដាសដោយស្បែកតែម្ខាងឬទាំងពីរខាង)

ស្គរ មានច្រើនប្រភេទ : (ទំ.១៤៣២)

- ស្គរ ខ្មែរ ឬ ស្គរអារក្ស
- ស្គរ ជ័យ
- ស្គរ ធំ

**ស្បូវ** (ស្មៅមួយប្រភេទ ស្លឹកវែងៗរឹងគគ្រាត)

ស្បូវ មាន២ប្រភេទ : (ទំ.១៤៥២)

- ស្បូវ ភ្លាំង
- ស្បូវ រណ្ដាស

**ស្ពៃ** (ដំណាំមួយពួកដាំយកធាង យកស្លឹក យកមើម ប្រើជាបន្លែ ជាអន្លក់ ឬ ប្រើការជ្រក់)

ស្ពៃ មានច្រើនប្រភេទ : (ទំ.១៤៥៦)

- ស្ពៃ ក្តោប
- ស្ពៃ ហាង
- ស្ពៃ មើម
- ស្ពៃ ស ឬ ស្ពៃញាំ
- ស្ពៃ ក្រអូប
- ស្ពៃ ទឹក
- ស្ពៃ ស្មៀម
- ស្ពៃ ទំពាំង

**ស្រល់** (ឈ្មោះឈើមួយប្រភេទ ស្លឹកល្អិតៗរឹងៗ)

ស្រល់ មាន២ប្រភេទ : (ទំ.១៤៧២)

- ស្រល់ កន្ទុយដំរី
- ស្រល់ ក្រហម

## ស្រែង

(ឈ្មោះរោគកើតនៅស្បែកចេញជាកណ្ដាប់គគ្រាតបណ្ដាលឱ្យរមាស់)

ស្រែង មានឈ្មោះច្រើនយ៉ាង : (ទំ.១៤៨៦)

- ស្រែង ផ្កា
- ស្រែង ដែក
- ស្រែង ផេះ
- ស្រែង កង្កែប

## ស្លែង (ឈ្មោះវល្លិពុល)

ស្លែង មាន២ប្រភេទ : (ទំ.១៤៩៤)

- ស្លែង ធំ
- ស្លែង តូច ឬ ស្លែងវល្លិ

## ស្វា (សត្វព្រៃមួយពួក

រូបរាងស្រដៀងនឹងមនុស្ស ជាសត្វរពឹសរពិលរប៉ូចសាវ៉ា,ក្រឡិចក្រឡុច,ខ្លះមានកន្ទុយ,ខ្លះឥតកន្ទុយ)

ស្វា មានច្រើនប្រភេទ : (ទំ.១៤៩៦)

- ស្វា ក្រិស
- ស្វា ខោ
- ស្វា ព្រាហ្មណ៍
- ស្វា អង្កត់
- ស្វា កណ្ដូង

## ស្វាយ (ឈ្មោះឈើដំណាំដើមធំ)

ស្វាយ មានច្រើនប្រភេទ : (ទំ.១៤៩៨)

- ស្វាយ កែវ
- ស្វាយ ក្បាលដំរី
- ស្វាយ ខ្ចិះ
- ស្វាយ ចេក
- ស្វាយ ទុរេន
- ស្វាយ ពងត្រង
- ស្វាយ ពុំសែន
- ស្វាយ មាស
- ស្វាយ មឹង
- ស្វាយ ស
- ស្វាយ អាត់
- ស្វាយ មឹងព្រួស
- ស្វាយ លហុង
- ស្វាយ លហួត
- ស្វាយ សង្កើច
- ស្វាយ ព្រៃ

## ស្រូវ

(ធញ្ញជាតិមួយប្រភេទសម្រាប់ចំអិនធ្វើជាអាហារ)

ស្រូវ មានច្រើនប្រភេទ :

- ស្រូវ នាងខ្មៅ
- ស្រូវ នាងស
- ស្រូវ នាងម៉ៅ
- ស្រូវ នាងខុន
- ស្រូវ នាងចិម

- ស្រូវ នាងហម
- ស្រូវ នាងឡុង
- ស្រូវ ផ្កាខ្ទឹម
- ស្រូវ ផ្កាដូង
- ស្រូវ ផ្កាស្នួល
- ស្រូវ ផ្កាស្លា
- ស្រូវ ផ្កាម្លិះ
- ស្រូវ ផ្កាខ្ញី
- ស្រូវ ផ្កាធ្នង់
- ស្រូវ ដំណើប
- ស្រូវ ខ្សាយ
- ស្រូវ ខ្លាញ់ក្អាម
- ស្រូវ ក្រចកចាប
- ស្រូវ កូនត្រី
- ស្រូវ ក្រយាសម្ពាន់
- ស្រូវ ពងហ៊ីង
- ស្រូវ សាយសាម៉ន
- ស្រូវ ចង្វាយផ្ដៅ
- ស្រូវ កំពីងពួយ
- ស្រូវ សុមាលី
- ស្រូវ ស្រាល
- ស្រូវ ស្រងៃ
- ស្រូវ ផ្ញើសយ
- ស្រូវ កំបោរ
- ស្រូវ កំផ្លេញ
- ស្រូវ ក្រលងភ្នំ

**ស្រមោច** (សុខុមសត្វច្រើនពួក មានប្រភេទផ្សេងៗគ្នា ជាសត្វមានសាមគ្គី ស្រុះគ្នា)

ស្រមោច មានច្រើនប្រភេទ :

- ស្រមោច កណ្ដាច់
- ស្រមោច ភ្លើង
- ស្រមោច យួន
- ស្រមោច អាត់

**ស្រាំង** (សុខុមសត្វមួយប្រភេទ មានស្លាបសន្ដានតាឱ តែរូបតូចជាងតាឱ មានទ្រនិចទិចចាប់ពើតក្ដៅ)

ស្រាំង មានច្រើនប្រភេទ :

- ស្រាំង ក្រហម
- ស្រាំង ដែក
- ស្រាំង ភ្លើង
- ស្រាំង រមៀត
- ស្រាំង អង្កាម

**អំពៅ** (ឈ្មោះដំណាំពួកមួយ ដើមមានថ្នាំងដូចឫស្សី សាច់ជ្រួត ជ្រាបពេញដោយទឹកមានរសផ្អែម)

អំពៅ មានច្រើនប្រភេទ :

(ទំ.១៨៥២)

- អំពៅ កែវ
- អំពៅ ក្អាម
- អំពៅ ខ្មៅ
- អំពៅ ដំឡាន់

- អំពៅ ត្រែង
- អំពៅ ស្អរ

## អំបូង

(ឈ្មោះចេកមានផ្លែវែងៗស្មើចុងស្មើដើម វេលាទុំសម្បុរសំបកបៃតងចាស់ ឬល្បើងចាស់ក៏មាន)

ចេកអំបូង មានច្រើនប្រភេទ : (ទំ.១៨៤៩)

- អំបូង ភ្លុក
- អំបូង ស្នែង
- អំបូង វល្លិ
- អំបូង ទេស

## អុត (ឈ្មោះរោគពួកមួយ)

អុត មានច្រើនប្រភេទ : (ទំ.១៧៨៦)

- អុត ក្តាម
- អុត ធំ
- អុត ព្រៃ
- អុត បាយ
- អុត ស្វាយ

## ឫសដូង (ឈ្មោះរោគពួកមួយ)

ឫសដូង មានច្រើនប្រភេទ : (ទំ.១០៨៤)

- ឫសដូង ច្រមុះ
- ឫសដូង វិល
- ឫសដូង រំហោក
- ឫសដូង បាត

## ឫស្សី

(តចសារជាតិមួយប្រភេទដុះទំពាំងបែកចេញជាគុម្ព ដើមមានថ្នាំង)

ឫស្សី មានច្រើនប្រភេទ : (ទំ.១០៨៦)

- ឫស្សី ស្រុក
- ឫស្សី ព្រៃ
- ឫស្សី រលៀក
- ឫស្សី ត្រាច់
- ឫស្សី ឃ្លៃ
- ឫស្សី ថ្ម
- ឫស្សី ទ្រនំមាន់
- ឫស្សី កែវ
- ឫស្សី បន្លា

## អង្រ្កង (សុខុមសត្វពួកស្រមោច

សម្បុរក្រហម ជើងវែងៗ នៅអាស្រ័យនឹងរុក្ខជាតិ ឬលតាជាតិ ប្រមូលក្រសោបស្លឹកឈើរស់ធ្វើសំបុក ខាំឈឺផ្សា កាលណាខាំមានបញ្ចេញទឹកម្ជូរត្រមកផង)

អង្រ្កង មាន២ប្រភេទ : (ទំ.១៩៧០)

- អង្រ្កង ទឹក ឬ អង្រ្កងផេះ
- អង្រ្កង ភ្លើង

**អណ្តែង** (ឈ្មោះត្រីអិល ក្បាលសំប៉ែត មានពុកមាត់ មានឆ្អឹងពីរមានពិស កាលណាមុតសាច់មនុស្សឈឺចាប់ពើត)

ត្រីអណ្តែង មាន២ប្រភេទ : (ទំ.១៥៩១)

- អណ្តែង ងាំង
- អណ្តែង ទន់

**អណ្តើក** (អដ្ឋិចម្មសត្វពួកមួយ មានស្នូកនិងពោះក្រាស់រឹង សណ្ឋានជាក្រឡាៗ មានជើង៤ៗខ្លី ក្បាលនិង ជើងលឹបលៀនបាន)

អណ្តើក មានច្រើនប្រភេទ : (ទំ.១៥៩១)

- អណ្តើក ភ្នែក
- អណ្តើក បិទមុខ ឬ អណ្តើកក្បិតមុខ
- អណ្តើក ព្រេច
- អណ្តើក សង្កល់

**អន្លូញ** (ឈ្មោះសំពត់ស្លៀកពួកមួយ)

អន្លូញ មាន៣ប្រភេទ : (ទំ.១៦៤១)

- អន្លូញ ស្មើ
- អន្លូញ មក្លាំ
- អន្លូញ ប៉ប៉ក

(អន្លូញទាំងបីប្រភេទនេះ ជាសំពត់សម្រាប់ស្លៀកប៉ុកប៉ឹនរបស់ ប្រជាជនខ្មែរសម័យពីដើម,សព្វថ្ងៃនេះគ្មានទេ)

**អន្សម** (ឈ្មោះនំធ្វើដោយអង្ករដំណើប ខ្ចប់ដោយស្លឹកស្រស់ ច្រើន ប្រើស្លឹកចេក មានរាងមូលរលស្មើចុងស្មើដើម ចម្អិនដោយស្ងោរឬអាំងក៏បាន)

អន្សម មានច្រើនប្រភេទ : (ទំ.១៦៤២)

- អន្សម ចេក
- អន្សម ជ្រូក
- អន្សម ដូង
- អន្សម អាំង

**អម្ពិល** (ឈ្មោះឈើពួកមួយ មានដើមធំ សាច់ស្វិត ស្លឹកល្អិតៗ មានរសជូរ,ផ្លែវែងៗ)

អម្ពិល មាន៣ប្រភេទ : (ទំ.១៦៧២)

- អម្ពិល ក្តារ
- អម្ពិល ក្តាម ឬ អម្ពិលអាចម៍ឆ្មា
- អម្ពិល ផ្អែម

**ចប់**